មាត្រា ៣៥ ._

ក-ការគ្រប់គ្រងរបស់អាណាប័កដើមខ្មែរ លើវិទ្យាស្ថានភាសាជាតិ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ-ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃ រតនាគារជាតិ នៃក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុ ។

គ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់តែងធ្វើការផ្ទៀងផ្ទាត់អធិការកិច្ច ឬការត្រួតពិនិត្យលើវិទ្យាស្ថានភាសាជាតិ នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខ័ណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

## ជំពូកទី IV

## អវសានបញ្ញត្តិ

**មាត្រា ៣៦ ._** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧ ._** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា ៣៨ ._** សំហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

★ ★ ★

# អនុក្រឹត្យលេខ ៤៦ អនក្រ.បក

## ស្តីពីការផ្ទេរភេណនាន

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៦

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០៧ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៨ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨

-បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការ គ្រប់គ្រង ឆ្នាំ ១៩៩៨

-បានឃើញប្រកាសលេខ ០១ ប្រ.សហវ. ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការចំណាត់ថ្នាក់ ចំណូល និង ចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .**_ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤.១០០លានរៀល (បួនពាន់មួយរយលានរៀល) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មក ជំពូក១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ជួសជុលតូច ) របស់ក្រសួងមហាផ្ទៃ ផ្នែក សន្តិសុខសាធារណៈសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

**មាត្រា ២ .**_ ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ទូទាត់បំណុល សំភារៈបរិក្ខារសងអោយក្រុមហ៊ុន ស្ពតិមិច ចំនួន ២.៨០០លានរៀល ( ពីរពាន់ប្រាំបីរយលានរៀល ) និង ក្រុមហ៊ុន គួ ហ៊្វីឡុងចំនួន ១.៣០០លានរៀល ( មួយពាន់បីរយលានរៀល ) ។

**មាត្រា ៣ .**_ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

★ ★ ★